**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ៖ សហមេធាវីការពារក្ដីលោក អោ អាន

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០២០

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង៖

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ៖

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ៖

ឈ្មោះមន្ត្រីដែលបានពិនិត្យ៖

ហត្ថលេខា៖

---

**សេចក្ដីសង្ខេបអញ្ញត្រកម្មរបស់ អោ អាន អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង**

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្ដី**

**មុំ លុយ្យ**

**រីឆាដ រ៉ូជើ**

(Richard ROGERS

**យ៉ូរេន ស្លាវតើ**

(Göran SLUITER)

**ចម្លងជូន៖**

**អង្គជំនុំជម្រះសាលាដំបូង**

ចៅក្រម **និល ណុន** ប្រធាន

ចៅក្រម **ក្លូឌា ហ្វេនស៍** (Claudia FENZ)

ចៅក្រម **យ៉ា សុខន**

ចៅក្រម **ម៉ាទីន ខារ៉ុបគីន** (Martin KAROPKIN)

ចៅក្រម **យូរ ឧត្តរា**

**សហព្រះរាជអាជ្ញា៖**

**ជា លាង**

**ប្រ៊ែនដា ជេ. ហូលីស**

(Brenda J. HOLLIS)

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/២**

## សេចក្តីផ្តើម

១. លោក អា អាន តាមរយៈសហមេធាវីការពារក្តីរបស់គាត់ (បន្ទាប់ពីនេះហៅកាត់ថា *"មេធាវីការពារក្តី"*) សូមដាក់សេចក្តីសង្ខេបអញ្ញត្រកម្មនេះ អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង (*"វិធានផ្ទៃក្នុង"*) នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (បន្ទាប់ពីនេះហៅកាត់ថា *"អ.វ.ត.ក"*)។

២. ដើម្បីបញ្ចៀសភាពមន្ទិល មេធាវីការពារក្តីនៅតែរក្សាជំហរថា សំណុំរឿង ០០៤/០២ មិនគួរត្រូវបានចាត់ទុកថាបានបញ្ជូនទៅជំនុំជម្រះឡើយ។ នៅក្នុង *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*[1] អង្គបុរេជំនុំជម្រះបានប្រកាសជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាជារឿងខុសច្បាប់[2] ប៉ុន្តែអង្គបុរេជំនុំជម្រះមិនទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ដើម្បីសម្រេចលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី និងសហព្រះរាជអាជ្ញាជាតិប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងទៅលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់[3]នោះទេ។ អនុលោមតាមវិធាន៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង ដីកាលើកលែងចោទប្រកាន់ត្រូវមានសុពលភាព ហើយសំណុំរឿងប្រឆាំងនឹង អោ អាន គួរត្រូវបានចាត់ទុកថារលត់តាមផ្លូវច្បាប់។

៣. ដោយគិតទៅដល់ពេលវេលាកំណត់ក្នុងការដាក់អញ្ញត្រកម្មនានាដូចមានចែងក្នុងវិធាន៨៩(១) នៃវិធានផ្ទៃក្នុង និង ដោយសារពុំមានការណែនាំពីអង្គជំនុំជម្រះសាលាដំបូង ស្តីពីសុពលភាព និងតារាងពេលវេលាសម្រាប់ដាក់អញ្ញត្រកម្មអនុលោមតាមវិធាន៨៩ នៃវិធានផ្ទៃក្នុងនោះ មេធាវីការពារក្តីសូមដាក់ជូននូវសេចក្តីសង្ខេបនៃអញ្ញត្រកម្មរបស់ខ្លួនអនុលោមតាមវិធាន៨៩(១)(ក) និង (ខ) នៃវិធានផ្ទៃក្នុង។ យើងខ្ញុំសូមលើកឡើងនូវការយល់ឃើញនានាដោយសង្ខេបសិន ដោយពេលវេលាមានកំណត់ និងចំនួនទំព័រកំណត់ដែលមានចែងក្នុងវិធានផ្ទៃក្នុង និងសេចក្តីណែនាំអនុវត្ត[4]។ មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេច ក្នុងការដាក់សារណាស្តីពីអញ្ញត្រកម្មទាំងនេះលំអិតជា

[1] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស (អបជ៦០) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍")* ឯកសារ **D359/24 និង D360/33** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩។

[2] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១២៤។

[3] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៦៩។

[4] សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(*"សេចក្តីណែនាំអនុវត្ត"*)មាត្រា ៥.១។

លាយលក្ខណ៍អក្សរ នៅពេលដែលមេធាវីការពារក្ដីទទួលបានពេលវេលាគ្រប់គ្រាន់ និងការបន្ថែមចំនួនទំព័រកំណត់ សម្រាប់ដាក់អញ្ញត្រកម្មជាលាយលក្ខណ៍អក្សរ ដោយអនុលោមតាមវិធាន ៣៩ (៤) នៃវិធានផ្ទៃក្នុង និង មាត្រា ៥.៤ នៃសេចក្ដីណែនាំអនុវត្ត។

៤. ទោះជាយ៉ាងណាក្ដី ដូចដែលយើងខ្ញុំធ្លាប់បានលើកឡើងនៅក្នុងលិខិតដែលបានផ្ញើជូនលោក-លោកស្រីចៅក្រមនាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩[៥] មេធាវីការពារក្ដីស្នើសុំអង្គជំនុំជម្រះសាលាដំបូងដោយគោរព មុននឹងពិនិត្យទៅលើអញ្ញត្រកម្មទាំងនេះ មេត្តាបញ្ជាក់ថា អង្គជំនុំជម្រះមិនបានទទួលយកសំណុំរឿង ០០៤/០២ មកពិនិត្យតាមផ្លូវច្បាប់នោះទេ។

៥. ដោយសារតែមានពេលវេលាកំណត់ដូចមានចែងក្នុងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង មេធាវីការពារក្ដីសូមដាក់ពាក្យសុំនេះជាភាសាអង់គ្លេសជាមុនសិន ចំណែកសំណៅបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយឲ្យបានឆាប់បំផុត។

## ប្រវត្តិនីតិវិធី

៦. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតបានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា នៅក្នុងសំណុំរឿង ០០៤/០២[៦]។

៧. នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាជាតិ បានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)[៧]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងចោទប្រកាន់[៨]។ នៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ

[៥] ក្រុមមេធាវីការពារក្ដី អោ អាន *"សំណើសុំការបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងនឹងមិនទទួលយកសំណុំរឿង ០០៤/០២ ទៅពិនិត្យតាមផ្លូវច្បាប់ទេ។ ជាជម្រើសម្យ៉ាងទៀត សំណើសុំបន្ថែមពេលវេលា និងការណែនាំសម្រាប់ដាក់អញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង"* (*"សំណើសុំការបញ្ជាក់"*) ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។

[៦] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស *ដីកាដំណោះស្រាយរបស់ ស.ច.ស.អ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ **D360** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស *ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន* (*"ដីកាលើកលែងចោទប្រកាន់"*) ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[៧] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស *បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជាតិទាក់ទងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនទៅជំនុំជម្រះ) ក្នុងសំណុំរឿង ០០៤/២* ឯកសារ **D360/8/1** ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៨។

[៨] សំណុំរឿងលេខ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស *បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិលើដីកា*

២០១៨ នោះដែរ មេធាវីការពារក្ដីបានដាក់បណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)[៩]។

៨. នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ អង្គបុរេជំនុំជម្រះបានចេញ *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍*។ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា ការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាជារឿងខុសច្បាប់[១០] ប៉ុន្តែអង្គបុរេមិនទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ ដើម្បីសម្រេចលើអង្គសេចក្ដីនៃសារណាបណ្ដឹងឧទ្ធរណ៍របស់ភាគីនោះទេ[១១]។

៩. នៅថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ មេធាវីការពារក្ដីបានផ្ញើលិខិតមួយច្បាប់ជូនអង្គជំនុំជម្រះសាលាដំបូង ដោយស្នើសុំការបញ្ជាក់ថាអង្គជំនុំជម្រះសាលាដំបូងនឹងមិនទទួលយកសំណុំរឿង ០០៤/០២ មកពិនិត្យតាមផ្លូវច្បាប់ទេ និង ជម្រើសម្យ៉ាងទៀតស្នើសុំបន្ថែមពេលវេលា និងការណែនាំពីសាលាដំបូង ដើម្បីដាក់អញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង[១២]។

១០. នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ *សារណាស្ដីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ* របស់ខ្លួនអនុលោមតាមវិធាន ៨០ នៃវិធានផ្ទៃក្នុង ជូនអង្គជំនុំជម្រះសាលាដំបូង[១៣]។

## ច្បាប់ជាធរមាន

១១. អនុលោមតាមវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង អញ្ញត្រកម្មពាក់ព័ន្ធនឹង (ក) យុត្តាធិការរបស់អង្គជំនុំ

---

*សម្រេចលើកលែងចោទប្រកាន់ អោ អាន (D359)* (*"បណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ"*) ឯកសារ **D359/3/1** ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។

[៩] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/កសចស *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤/២* ឯកសារ **D360/5/1** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨។

[១០] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១២៤។

[១១] សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ កថាខណ្ឌ ១៦៩។

[១២] សំណើសុំការបញ្ជាក់។

[១៣] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/អជសដ *សារណាស្ដីពីបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញអនុលោមតាមវិធាន ៨០ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ជាមួយឧបសម្ព័ន្ធ ក សម្ងាត់* (*"បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ"*) ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០។

ជម្រះ និង (ខ) ការរលត់បណ្តឹងអាជ្ញា "ត្រូវលើកឡើងយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ ក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរ បើមិនដូច្នេះទេអញ្ញត្រកម្មនោះមិនអាចត្រូវបានទទួលយកឡើយ"។

១២. វិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុងចែងថា ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបាន ដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ សេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គបុរេជំនុំជម្រះទៅលើដីកានោះត្រូវតម្កល់ទុកជាបានការ។

១៣. មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។ គោលការណ៍ដូចគ្នានេះក៏ត្រូវបានទទួលស្គាល់ជាសាកល ដូចមានចែងនៅក្នុងមាត្រា ១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែរ។

១៤. អនុលោមតាមមាត្រា ២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាចែងថា "កិច្ចព្រមព្រៀងនេះទទួលស្គាល់ផងដែរថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរូបបុគ្គលជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម [...]"។

១៥. ការជំនុំជម្រះដោយយុត្តិធម៌មានចែងនៅក្នុងមាត្រា ៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា, មាត្រា ៣៣ ដល់ ៣៥ ថ្មី នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(*"ច្បាប់បង្កើតអ.វ.ត.ក"*) និង វិធាន ២១ នៃវិធានផ្ទៃក្នុង។

## សេចក្តីសង្ខេបអញ្ញត្រកម្មរបស់ អៀង សារី

១៦. មេធាវីការពារក្តីសូមធ្វើអញ្ញត្រកម្មដោយសង្ខេប ស្របទៅតាមពេលវេលាកំណត់ដែលមានចែងក្នុងវិធាន ៨៩(១) នៃវិធានផ្ទៃក្នុង ដូចខាងក្រោម៖

I. **អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការនៅលើសំណុំរឿង ០០៤/០២ ទេ ដោយសារសំណុំរឿងនេះត្រូវបានលើកលែងទោសប្រកាន់ហើយ (វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង)៖**

១៧. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការដើម្បីជំនុំជម្រះក្តី អៀង សារី ទេ ដោយសារសំណុំរឿងប្រឆាំងរូបគាត់ត្រូវបានលើកលែងទោសប្រកាន់ និងដោយសារភាពជាប់គាំង ដោយមិនមានចែងក្នុងវិធានណាមួយជាក់លាក់ ដែលកើតឡើងដោយសារដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និង

ផ្ទុយគ្នានេះ ត្រូវដោះស្រាយជាប្រយោជន៍ដល់ អោ អាន អនុលោមតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង មាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។

១៨. ដីកាលើកលែងចោទប្រកាន់ក្នុងសំណុំរឿង០០៤/០២ អនុលោមតាមវិធាន៦៧(២) នៃវិធានផ្ទៃក្នុង ត្រូវបានចេញនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨[១៤]។ សហព្រះរាជអាជ្ញាអន្តរជាតិបានប្តឹងឧទ្ធរណ៍លើដីកាលើកលែងចោទប្រកាន់[១៥] តែទោះជាយ៉ាងណាក្តីអង្គបុរេជំនុំជម្រះមិនទទួលបានសំឡេងគាំទ្រភាគច្រើនលើសលប់ ដើម្បីសម្រេចទៅលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នោះទេ[១៦]។ អនុលោមតាមវិធាន ៧៧(១៣)(ក) នៃវិធានផ្ទៃក្នុង ប្រសិនបើសម្លេងភាគច្រើនដែលតម្រូវមិនអាចរកបានដើម្បីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដែលមិនមែនជាដីកាបញ្ជូនរឿងទៅជំនុំជម្រះសេចក្តីសម្រេចដែលមិនមានសម្លេងគាំទ្ររបស់អង្គជំនុំជម្រះទៅលើដីកានោះ ត្រូវតម្កល់ទុកជាបានការ។ ហេតុនេះ ដីកាលើកលែងចោទប្រកាន់នៅមានសុពលភាពមិនប៉ះពាល់ដោយបណ្តឹងឧទ្ធរណ៍ឡើយ។

១៩. អង្គហេតុដែលថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះក៏អាចនៅមានសុពលភាពអនុលោមតាមវិធាន ៧៧(១៣)(ខ)នៃវិធានផ្ទៃក្នុងនោះ[១៧] ពុំជាប់ពាក់ព័ន្ធនឹងសុពលភាពជាបន្តនៃដីកាលើកលែងចោទប្រកាន់នោះឡើយ។ ចំណែកគោលការណ៍ជាបន្តនៃកិច្ចស៊ើបសួរ ដែលមានក្នុងមាត្រា ២៣ថ្មី ដើម្បីដោះស្រាយករណីខ្វែងយោបល់គ្នាទៅលើដីកាដំណោះស្រាយតែមួយ ក៏មិនអាចយកមកសំអាងដើម្បីបដិសេធនូវអត្ថិភាព និងសុពលភាពបន្តដីកាលើកលែងចោទប្រកាន់នោះឡើយ។

២០. ដូចសម្លេងគាំទ្រភាគច្រើនរបស់ចៅក្រមនៅអង្គបុរេជំនុំជម្រះបានសម្រេច ក្របខណ្ឌគតិយុត្តិនៅ អ.វ.ត.ក មិនអាចដោះស្រាយនូវភាពជាប់គាំងដោយសារមានដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាបានឡើយ[១៨]។ អនុលោមតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានចែងក្នុងមាត្រា៣៨នៃរដ្ឋធម្មនុញ្ញកម្ពុជា និង មាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ រាល់ភាពជាប់គាំង និងភាពមិនច្បាស់

---

[១៤] ដីកាលើកលែងចោទប្រកាន់។

[១៥] បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ។

[១៦] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ១៦៩។

[១៧] ឧទាហរណ៍ បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ កថាខណ្ឌ ២។

[១៨] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩៥។

លាស់ទាំងអស់ត្រូវយកមកដោះស្រាយជាប្រយោជន៍ដល់ជនជាប់ចោទពោលគឺ អោ អាន[១៩]។ ហេតុនេះ ដីកាលើកលែងចោទប្រកាន់ត្រូវមានឧត្តមភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយ អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការជំនុំជម្រះលើសំណុំរឿង០០៤/០២ ឡើយ។

## II. សុពលភាពជាបន្តនៃដីកាលើកលែងចោទប្រកាន់តម្រូវឲ្យរំលត់បណ្តឹងអាជ្ញា (វិធាន ៨៩ (១)(ខ) នៃវិធានផ្ទៃក្នុង)÷

២១. ជាងនេះទៀត ឬ ជាជម្រើសម្យ៉ាងទៀត ដោយសារសំអាងហេតុនានាដែលបានលើកឡើងនៅក្នុង អញ្ញត្រកម្មទីមួយខាងលើ សុពលភាពជាបន្តនៃដីកាលើកលែងចោទប្រកាន់តម្រូវឲ្យអង្គជំនុំជម្រះ សាលាដំបូងរំលត់បណ្តឹងអាជ្ញា។ សេចក្តីសម្រេចផ្សេងពីនេះ គឺផ្ទុយនឹងគោលការណ៍ *វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលមានចែងក្នុងមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា និង មាត្រា១៤(២) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ជំហរនេះបានទទួល ការគាំទ្រដោយចៅក្រមភាគច្រើននៅដំណាក់កាលមុនសវនការ (ដំណាក់កាលស៊ើបអង្កេត)[២០]។

## III. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការបុគ្គលទៅលើ អោ អាន ទេ (វិធាន ៨៩ (១)(ក) នៃវិធានផ្ទៃក្នុង)÷

២២. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការបុគ្គលទៅលើ អោ អាន ទេ ដោយសារ អោ អាន ពុំមែនជាមេដឹកនាំជាន់ខ្ពស់របស់ខ្មែរក្រហម ហើយក៏ពុំមែនជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះ ឧក្រិដ្ឋកម្មកើតឡើងក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យនោះឡើយ។

២៣. យុត្តាធិការបុគ្គលរបស់តុលាការត្រូវបានកម្រិតដោយលក្ខណៈវិនិច្ឆ័យសមហេតុផល ដោយបាន កម្រិតនិយមន័យយ៉ាងចង្អៀតនៅក្នុងមាត្រា ២(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជា គឺ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។ ការកម្រិត ផ្នែកយុត្តាធិការត្រូវបកស្រាយទៅតាមអត្ថន័យធម្មតា បរិបទ និងគោលបំណងនៃកិច្ចព្រមព្រៀង នោះ។ ដើម្បីផ្តន្ទាទោសជនជាប់ចោទ អង្គជំនុំជម្រះសាលាដំបូងត្រូវមានជំនឿដោយគ្មានវិមតិ សង្ស័យថា អោ អាន ស្ថិតក្នុងប្រភេទណាមួយក្នុងចំណោមជនទាំងពីរប្រភេទនេះ[២១]។

---

[១៩] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩៨ និង ៣០១។

[២០] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩៨ និង ៣០១។

[២១] វិធាន ៨៧(១) នៃវិធានផ្ទៃក្នុង។

២៤. ប្រវត្តិនៃការចរចាបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា[២២] និងគោលជំហរស្របគ្នា និងច្បាស់លាស់របស់រាជរដ្ឋាភិបាលកម្ពុជា[២៣] សហព្រះរាជអាជ្ញាជាតិ[២៤] សហចៅក្រមស៊ើបអង្កេតជាតិ[២៥] និងចៅក្រមជាតិនៅអង្គបុរេជំនុំជម្រះ[២៦] តម្រូវឱ្យបកស្រាយពាក្យពេចន៍ទាំងនេះយ៉ាងចង្អៀត គឺថា៖ (១) យុត្តាធិការបុគ្គលរបស់តុលាការគួរត្រូវបានកម្រិតត្រឹមតែ "មេដឹកនាំ" ដែលបានបង្កើត កំណត់ ឬបកស្រាយគោលនយោបាយ ឬបុគ្គលដែលមិនអាចខ្វះបានក្នុងការអនុវត្តគោលនយោបាយ និង (២) ពាក្យថា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" តម្រូវឱ្យមានការវិភាគប្រៀបធៀប ចំពោះការចូលរួមចំណែករបស់កម្មាភិបាលខ្មែរក្រហមទៅនឹងឧក្រិដ្ឋកម្មក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដើម្បីកំណត់អត្តសញ្ញាណបុគ្គលដែលដើរតួនាទីកាន់តែធំធេងក្នុងការប្រព្រឹត្តិឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតនៅលើទឹកដីកម្ពុជាប្រជាធិបតេយ្យទាំងមូល[២៧]។

---

[២២] ឧទាហរណ៍ Heder "ការវាយតម្លៃទៅលើការចរចាដែលនាំឱ្យមានការបង្កើតយុត្តាធិការបុគ្គលរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" (*"ការវាយតម្លៃរបស់ Heder"*) (ថ្ងៃទី០១ ខែសីហា ឆ្នាំ២០១១) ទំព័រ ១៤, ២០ (ភាសាអង់គ្លេស) ភ្ជាប់ជាឧបសម្ព័ន្ធ ១។ Scheffer "ប្រវត្តិនៃការចរចាបង្កើតយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក" (*"ប្រវត្តិចរចា"*) *Cambodia Tribunal Monitor* (ថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១១) ទំព័រ ៧ (ភាសាអង់គ្លេស) ភ្ជាប់ជាឧបសម្ព័ន្ធ ២។

[២៣] ឧទាហរណ៍ សេចក្តីថ្លែងការណ៍របស់ឧបនាយករដ្ឋមន្ត្រី សុខ អាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី (ដកស្រង់ពីសេចក្តីថ្លែងការនៅឯមហាសន្និបាតលើកទី ៣៤ នៃអាណត្តិទី ៥ របស់គណបក្សប្រជាជនកម្ពុជា ថ្ងៃទី២៥-២៦ ខែមេសា ឆ្នាំ២០០៩) ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០០៩ ទំព័រ ១ ភ្ជាប់ជាឧបសម្ព័ន្ធ ៣។ Sokha & O-Toole "សម្តេច ហ៊ុន សែន ផ្ញើជូនលោក Ban Ki-moon៖ សំណុំរឿង ០០២ ជាការជំនុំជម្រះចុងក្រោយនៅ អ.វ.ត.ក" *The Phnom Penh Post* (ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០) ភ្ជាប់ជាឧបសម្ព័ន្ធ ៤។

[២៤] ឧទាហរណ៍ សំណុំរឿងលេខ ០០១/១៨-១១-២០០៨-អ.វ.ត.ក/អបជ *ចម្លើយតបរបស់សហព្រះរាជអាជ្ញាជាតិទៅនឹងសេចក្តីណែនាំរបស់អង្គបុរេជំនុំជម្រះផ្តល់ព័ត៌មានបន្ថែមពិស្តារ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០០៩ និង សេចក្តីសង្កេតបន្ថែមរបស់សហព្រះរាជអាជ្ញាជាតិ* (*"ព័ត៌មានបន្ថែមពិស្តាររបស់ ស.ព.ជ"*) ឯកសារ **D17** ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ១០, ១៣។

[២៥] ឧទាហរណ៍ សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៤ (សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/កសចស) ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១។ ដីកាលើកលែងចោទប្រកាន់ផ្នែកសម្រេចសេចក្តី។

[២៦] ឧទាហរណ៍ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/កសចស *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍លើសេចក្តីសម្រេចលើសំណើលើកទីប្រាំរបស់ អោ អាន សុំបំពេញកិច្ចស៊ើបសួរ* (*"សេចក្តីពិចារណាលើសំណើទីប្រាំរបស់ អោ អាន"*) ឯកសារ **D260/1/1/3** ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ កថាខណ្ឌ ២៧-២៨។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ២៩៣។

[២៧] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណា

២៥. សំណុំរឿងប្រឆាំង អោ អាន មិនបានបំពេញទៅតាមលក្ខណៈវិនិច្ឆ័យផ្នែកយុត្តាធិការបុគ្គលជាធរមាន ចំពោះបទដ្ឋាននៃភ័ស្តុតាងជាធរមានទេ ទោះបីជាក្នុងកម្រិតអតិបរមារបស់វាក៏ដោយ[២៨]។ សំណុំរឿងនេះមិនបានបង្ហាញថា អោ អាន ជា "មេដឹកនាំ" ដែលបង្កើត កំណត់ ឬបកស្រាយគោលនយោបាយរបស់ខ្មែរក្រហម ឬជាបុគ្គលដែលមិនអាចខ្វះបានក្នុងការអនុវត្តគោលនយោបាយនោះទេ។ ពុំមានភ័ស្តុតាងធ្ងន់ធ្ងរ និងអាចទុកចិត្តបានថា អោ អាន មានតួនាទីអ្វីធំធេងនៅថ្នាក់ភូមិភាគកណ្តាលទេ (ឬថា ទោះបីគាត់មានតួនាទីធំធេង ក៏មិនអាចបញ្ចូលគាត់ទៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការបានដែរ)។ ជាងនេះទៀត គេពុំអាចសន្និដ្ឋានដោយសមហេតុផលពីភ័ស្តុតាងបានថា អោ អាន មានអំណាចសម្រេចចិត្តជាក់ស្តែងធំធេង ឬចូលរួមក្នុងឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅថ្នាក់តំបន់ ៤១ បានឡើយ។ ជាកម្រិតអតិបរមា សំណុំរឿងប្រឆាំង អោ អាន គឺថាគាត់ជាមនុស្សស្ថិតក្រោមបង្គាប់របស់ កែ ពក ដែលជាអ្នកអនុវត្តយ៉ាងខ្ជាប់ខ្ជួនទៅតាមបទបញ្ជាការណែនាំ និងគោលការណ៍ដែលមជ្ឈិមបក្សបានកំណត់។ ជាងនេះទៀត សំណុំរឿងនេះទទួលរងភាពអាប់ឱនយ៉ាងធ្ងន់ធ្ងរដោយសារគម្លាតភ័ស្តុតាង សាក្សីមិនអាចជឿជាក់បាន ការស៊ើបអង្កេតមិនត្រឹមត្រូវ និងភាពផ្ទុយគ្នាទៅលើបញ្ហានានា រួមមាន ការចោទប្រកាន់ពីពេលវេលាដែល អោ អាន បានទៅដល់ភូមិភាគកណ្តាល ការចោទប្រកាន់ពីការចូលរួមរបស់គាត់ក្នុងការបោសសម្អាតនៅភូមិភាគកណ្តាល ការចោទប្រកាន់ពីតំណែង និងតួនាទីរបស់គាត់ក្នុងតំបន់ ៤១ ការចោទប្រកាន់ពីចេតនា ការដឹងឮ និងការចូលរួមរបស់គាត់ ពាក់ព័ន្ធនឹងការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ទៅលើជនជាតិចាម គោលនយោបាយនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការចោទប្រកាន់ពីឧក្រិដ្ឋកម្មនានានៅតាមមន្ទីរសន្តិសុខ និងទីតាំងឧក្រិដ្ឋកម្មផ្សេងទៀត ក្នុងតំបន់ ៤១[២៩]។

២៦. ជាងនេះទៀត សំណុំរឿងប្រឆាំង អោ អាន មិនបានបង្ហាញថាការចោទប្រកាន់ពីការចូលរួមចំណែករបស់គាត់ក្នុងអំពើឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមមានភាពធំធេងគ្រប់គ្រាន់ នៅក្នុងបរិបទរបស់កម្មាភិបាលខ្មែរក្រហមទាំងអស់ផ្សេងទៀត ដែលបានប្រព្រឹត្តអំពើឃោរឃៅនៅលើទឹកដីកម្ពុជា

---

បន្ថែមទៀត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងផ្តល់ការអនុញ្ញាតឱ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

[២៨] ជាងនេះទៀត សំណុំរឿងនេះមិនបានទទួលការគាំទ្រដោយចៅក្រមភាគច្រើននៅអង្គបុរេជំនុំជម្រះ ទៅតាមបទដ្ឋានអប្បបរមាដែលអនុវត្តនៅដំណាក់កាលមុនការជំនុំជម្រះលើអង្គសេចក្តីនោះឡើយ។

[២៩] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងការជំទាស់នីមួយៗដែលបានលើកឡើងនៅក្នុងកថាខណ្ឌនេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឱ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

ប្រជាធិបតេយ្យទាំងមូលដើម្បីបញ្ចូលរូបគាត់ទៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះឡើយ។

២៧. ចុងក្រោយ សំណុំរឿងប្រឆាំង អោ អាន មិនឈានដល់កម្រិតនៃស្ថានទម្ងន់ដែលបញ្ចូលរូបគាត់ទៅក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ចំពោះឧក្រិដ្ឋកម្មក្នុងសម័យខ្មែរក្រហមឡើយ ទោះបីជាក្នុងកម្រិតអតិបរមារបស់វាក៏ដោយ។

២៨. អាស្រ័យទៅតាមសំអាងហេតុទាំងនេះអង្គជំនុំជម្រះសាលាដំបូង ពុំមានយុត្តាធិការបុគ្គលដើម្បីជំនុំជម្រះ អោ អាន ចំពោះឧក្រិដ្ឋកម្មនានាដែលបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ។

## IV. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្តីនៅលើឧក្រិដ្ឋកម្មជាតិ ដែលបានប្រព្រឹត្តឡើងនៅចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ (វិធាន ៨៩(១)(ក)នៃវិធានផ្ទៃក្នុង)÷

២៩. អង្គជំនុំជម្រះសាលាដំបូង ពុំមានយុត្តាធិការដើម្បីកាត់ទោស អោ អាន ចំពោះការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់ ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួម ជាទម្រង់នៃការទទួលខុសត្រូវនោះឡើយ។ អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការដើម្បីកាត់ទោស អោ អាន ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាបទមនុស្សឃាតគិតទុកជាមុន អនុលោមតាមក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ឡើយ ដោយសារតែអាជ្ញាយុកាលសម្រាប់ធ្វើការចោទប្រកាន់ឧក្រិដ្ឋកម្មជាតិដែលបានប្រព្រឹត្តឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានកន្លងផុតទៅហើយ[៣០]។ កាលពីមុន អង្គជំនុំជម្រះសាលាដំបូងមិនអាចរកសម្លេងភាគច្រើនលើសលប់ដើម្បីសម្រេចលើបញ្ហានេះបានទេ និងបានសម្រេចថា ជនជាប់ចោទនៅក្នុងសំណុំរឿង០០១ និង០០២ មិនអាចត្រូវបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មជាតិបានឡើយ[៣១]។ ឧក្រិដ្ឋកម្មជាតិដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងប្រទេសកម្ពុជា នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ

---

[៣០] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឱ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

[៣១] សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជសដ *សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី* ឯកសារ E187 ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៧-៣៥, ៣៩-៥៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ៥។ មេធាវីការពារក្តីយល់ស្របតាមសំអាងហេតុរបស់ចៅក្រមអន្តរជាតិនៅក្នុងសេចក្តីសម្រេចនេះ។

១៩៧៩ គឺជាកម្មវត្ថុនៃអាជ្ញាយុកាលដែលមានរយៈពេល១០ឆ្នាំ[៣២]។ ដោយសារថាឧក្រិដ្ឋកម្មនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តនៅចន្លោះចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់ត្រឹមថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ រយៈពេលអាជ្ញាយុកាល ១០ឆ្នាំបានកន្លងផុតទៅហើយ ដែលយ៉ាងយូរបំផុតត្រឹមថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៩។ មិនមានភ័ស្តុតាងបង្ហាញថាថិរវេលានៃអាជ្ញាយុកាលត្រូវបានផ្តាច់ឡើយ។ លើសពីនេះទៀត ប្រសិនបើមានភាពមិនប្រាកដប្រជាអំពីថិរវេលានៃអាជ្ញាយុកាល វិមតិសង្ស័យណាមួយពាក់ព័ន្ធនឹងការអនុវត្តចំពោះឧក្រិដ្ឋកម្មជាតិដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ត្រូវបានជាប្រយោជន៍ដល់ អោ អាន[៣៣]។ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូង ពុំមានយុត្តាធិការលើរឿងក្តីទៅលើឧក្រិដ្ឋកម្មជាតិដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។

## V. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្តីនៅលើការប្រព្រឹត្តដូចបានចោទប្រកាន់ ដោយផ្អែកនៅលើសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវនោះឡើយ (វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង)÷

៣០. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការដើម្បីកាត់ទោស អោ អាន ចំពោះអំពើដែលត្រូវបានចោទប្រកាន់ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវនោះឡើយ។ សហឧក្រិដ្ឋកម្មរួមពុំមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់កម្ពុជានៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ នោះឡើយ។ ពុំមានការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈទូលំទូលាយ និងស៊ីសង្វាក់គ្នា ដែលគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួមនៅក្នុងពេលវេលាពាក់ព័ន្ធឡើយ ខណៈដែលមានភ័ស្តុតាងផ្ទុយគួរឲ្យជឿជាក់បាន[៣៤]។ លើសពីនេះទៀត ពុំ

---

[៣២] ព្រះរាជាណាចក្រកម្ពុជា ('ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦') មាត្រា ១០៩, ១១១,១១២, ១១៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៦៤) មាត្រា ៣៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក-កសចស *ការជម្រាបជូនអំពីក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងសំណើសុំផ្តល់ការបញ្ជាក់លើក្រមផ្លូវការ* ឯកសារ E91/6 ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក-កសចស *លិខិតពីទីស្តីការគណៈរដ្ឋមន្ត្រី អំពីក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦* ឯកសារ E91/6/1 ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩។

[៣៣] មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។

[៣៤] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឲ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

មានយុត្តិសាស្ត្រ ឬការអនុវត្តរបស់រដ្ឋដែលគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ដូចដែលយកមកអនុវត្តនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ (ឧទាហរណ៍ ពុំមានការកំណត់និយមន័យច្បាស់លាស់អំពីក្រុមសហឧក្រិដ្ឋកម្មរួម ការពង្រីកវិសាលភាពភូមិសាស្ត្រមិនត្រឹមត្រូវនៃសហឧក្រិដ្ឋកម្មរួម និងការដាក់បញ្ចូលគ្នានូវគោលបំណងរួមផ្សេងៗគ្នារបស់ក្រុមសហឧក្រិដ្ឋកម្មរួមជាច្រើនក្រុម)[៣៥]។ ក្នុងករណីដែលមានភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលនៅជាធរមាននោះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តច្បាប់ដែលផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះអង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្តីទៅលើការប្រព្រឹត្តដូចបានចោទប្រកាន់ ដោយផ្អែកលើសហឧក្រិដ្ឋកម្មរួមនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ។

**VI. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្តីទៅលើការប្រព្រឹត្តដូចបានចោទប្រកាន់ ដោយផ្អែកទៅលើការរៀបចំផែនការ ជាទម្រង់នៃការទទួលខុសត្រូវនោះឡើយ (វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង)៖**

៣១. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការដើម្បីកាត់ទោស អៀង សារី ចំពោះអំពើដែលត្រូវបានចោទប្រកាន់ដោយផ្អែកលើការរៀបចំផែនការជាទម្រង់នៃការទទួលខុសត្រូវនោះឡើយ។ ការរៀបចំផែនការពុំមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់កម្ពុជា នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ។ ពុំមានការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈទូលំទូលាយ និងស៊ីសង្វាក់គ្នា ដែលគាំទ្រអត្ថិភាពរបស់វានៅក្នុងពេលវេលាពាក់ព័ន្ធឡើយ ខណៈដែលមានភស្តុតាងផ្ទុយគួរឲ្យជឿជាក់បាន[៣៦]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្តីទៅលើការប្រព្រឹត្តដូចបានចោទប្រកាន់ ដោយផ្អែកលើការរៀបចំផែនការ នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ។

**VII. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្តីទៅលើការប្រព្រឹត្តដូចបានចោទប្រកាន់ ដោយផ្អែកទៅលើការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវនោះឡើយ (វិធាន ៨៩(១)(ក)នៃវិធានផ្ទៃក្នុង)៖**

---

[៣៥] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឲ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

[៣៦] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឲ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

៣២. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការដើម្បីកាត់ទោស អោ អាន ចំពោះអំពើដែលត្រូវបានចោទប្រកាន់ដោយផ្អែកលើការទទួលខុសត្រូវរបស់ថ្នាក់លើ ជាទម្រង់នៃការទទួលខុសត្រូវនោះឡើយ។ ការទទួលខុសត្រូវរបស់ថ្នាក់លើដែលអាចអនុវត្តបានចំពោះមេបញ្ជាការស៊ីវិលនៅក្រៅបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ពុំមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវ អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់កម្ពុជា នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ។ ពុំមានការអនុវត្តរបស់រដ្ឋដែលមានលក្ខណៈទូលំទូលាយ និងស៊ីសង្វាក់គ្នា ដែលគាំទ្រអត្ថិភាពរបស់វានៅក្នុងពេលវេលាពាក់ព័ន្ធឡើយ ខណៈដែលមានភស្តុតាងផ្ទុយគួរឲ្យជឿជាក់បាន[៣៧]។ លើសពីនេះទៀត ពុំមានយុត្តិសាស្ត្រ ឬការអនុវត្តរបស់រដ្ឋដែលគាំទ្រអត្ថិភាពនៃការទទួលខុសត្រូវរបស់ថ្នាក់លើ ដូចដែលយកមកអនុវត្តនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ (ឧទាហរណ៍ ការខកខានមិនបានអនុវត្តលក្ខខណ្ឌតម្រូវហេតុ និងផល និងលក្ខខណ្ឌ*ធាតុផ្សំអត្តនោម័ត* មិនត្រឹមត្រូវ)[៣៨]។ ក្នុងករណីដែលមានភាពមិនប្រាកដប្រជាពាក់ព័ន្ធនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលនៅជាធរមាននោះ អង្គជំនុំជម្រះសាលាដំបូងត្រូវតែអនុវត្តច្បាប់ដែលផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ពុំមានយុត្តាធិការលើរឿងក្តីទៅលើការប្រព្រឹត្តដូចបានចោទប្រកាន់ដោយផ្អែកលើការទទួលខុសត្រូវរបស់ថ្នាក់លើនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។

## VIII. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្តីនៅលើឧក្រិដ្ឋកម្មក្រោមទម្រង់ជាអំពើអនុស្សធម៌ផ្សេងៗទៀត ដូចបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ (វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង)÷

៣៣. អង្គជំនុំជម្រះសាលាដំបូង ពុំមានយុត្តាធិការដើម្បីកាត់ទោស អោ អាន ចំពោះការប្រព្រឹត្តដែលត្រូវបានចាត់ទុកថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះឡើយ ដោយហេតុថា និយមន័យដែលយកមកអនុវត្តនោះពុំមានមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់កម្ពុជានៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ។ និយមន័យនេះបំបាត់ចោលនូវតម្រូវការក្នុងការបង្ហាញអំពី "ពិរុទ្ធភាពជាមូលដ្ឋាន"នៃការប្រព្រឹត្ត ព្រមទាំងបដិសេធចោលនូវតម្រូវការក្នុងការថែងអំពីធាតុផ្សំនៃបទល្មើសដែលត្រូវបានចោទប្រកាន់។ លើសពីនេះទៀត

---

[៣៧] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឲ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

[៣៨] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឲ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

និយមន័យនេះ ខកខានមិនបានអនុវត្ត*ធាតុផ្សំអត្តនោម័ត*ត្រឹមត្រូវ។ និយមន័យនេះ រំលោភលើច្បាប់ទំនៀមទម្លាប់អន្តរជាតិជាធរមាន និងគោលការណ៍នីត្យានុកូលភាព[៣៩]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូង ពុំមានយុត្តាធិការលើរឿងក្ដីទៅលើការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់ថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។

**IX. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្ដីទៅលើឧក្រិដ្ឋកម្មក្រោមទម្រង់ជាការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឡើយ (វិធាន ៨៩(១)(ក)នៃវិធានផ្ទៃក្នុង)÷**

៣៤. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការដើម្បីកាត់ទោស អៀង សារី ចំពោះឧក្រិដ្ឋកម្មក្រោមទម្រង់ជាអាពាហ៍ពិពាហ៍ដោយបង្ខំ ដែលត្រូវបានចោទប្រកាន់ថាជាអំពើអមនុស្សធម៌ផ្សេងទៀតនោះឡើយ។ អាពាហ៍ពិពាហ៍ដោយបង្ខំពុំមានអត្ថិភាពជាឧក្រិដ្ឋកម្ម អនុលោមតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់កម្ពុជានៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនបានបង្ហាញអំពីពិរុទ្ធភាពជាមូលដ្ឋាននៃអាពាហ៍ពិពាហ៍ដោយបង្ខំ មិនបានបង្ហាញពីភាពខុសគ្នារវាងអាពាហ៍ពិពាហ៍ដោយបង្ខំ និងអាពាហ៍ពិពាហ៍ដោយការផ្សំផ្គុំ មិនបានបង្ហាញថាអាពាហ៍ពិពាហ៍ដោយបង្ខំមានលក្ខណៈ និង ភាពធ្ងន់ធ្ងរស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មផ្សេងទៀតប្រឆាំងនឹងមនុស្សជាតិ និងដាក់បញ្ចូលគ្នាមិនត្រឹមត្រូវនូវអំពើនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈដើម្បីបង្កើនការយល់ឃើញអំពីភាពធ្ងន់ធ្ងរពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ[៤០]។ ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្ដីទៅលើការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់ថាជាអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។

**X. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្ដីទៅលើឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ (វិធាន ៨៩(១)(ក) នៃវិធានផ្ទៃក្នុង)÷**

៣៥. អង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការដើម្បីកាត់ទោស អៀង សារី ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដូចដែលបានកំណត់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។ ដីកាបញ្ជូនរឿងទៅជំនុំ

---

[៣៩] មេធាវីការពារក្ដីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្ដល់នូវព័ត៌មានពិស្ដារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្ដល់ការអនុញ្ញាតឲ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

[៤០] មេធាវីការពារក្ដីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្ដល់នូវព័ត៌មានពិស្ដារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្ដល់ការអនុញ្ញាតឲ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

ជម្រះបំបាត់ចោលនូវលក្ខខណ្ឌតម្រូវនៃធាតុផ្សំបរិបទសម្រាប់ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍។ ដីកានេះក៏អនុវត្ត*ធាតុផ្សំអត្តនោម័ត*មិនត្រឹមត្រូវផងដែរ (ឧទាហរណ៍ ខកខានមិនបានតម្រូវឲ្យចារីកំណត់ក្រុមគោលដៅជាវិជ្ជមានដើម្បីបំពេញធាតុផ្សំ "ជាអាទិ៍")។ ប្រការនេះមិនស៊ីសង្វាក់គ្នាជាមួយនឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់កម្ពុជា នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ[៤១]។ ហេតុដូច្នេះអង្គជំនុំជម្រះសាលាដំបូងពុំមានយុត្តាធិការលើរឿងក្តីទៅលើការប្រព្រឹត្តដែលត្រូវបានចោទប្រកាន់ថាជាអំពើប្រល័យពូជសាសន៍នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះឡើយ។

## XI. ការរំលោភបំពាននៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅក្នុងកិច្ចស៊ើបសួរនាំងមូលតម្រូវឲ្យការរំលត់បណ្តឹងអាជ្ញា (វិធាន ៨៩(១)(ខ) នៃវិធានផ្ទៃក្នុង)៖

៣៦. សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អោ អាន ត្រូវបានរំលោភបំពានយ៉ាងខ្លាំងនៅទូទាំងកិច្ចដំណើរការនីតិវិធីទាំងនេះ។ នៅក្នុងការវាយតម្លៃអំពីភាពត្រឹមត្រូវទូទៅនៃកិច្ចដំណើរការនីតិវិធី ចៅក្រមមានតួនាទីពិចារណាទៅលើការរំលោភបំពាននីមួយៗនៅក្នុងបរិបទរួមនៃដំណាក់កាលស៊ើបអង្កេតទាំងមូល ក៏ដូចជាផលប៉ះពាល់រួមនៃការរំលោភបំពានទាំងអស់ទៅលើលទ្ធភាពរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌[៤២]។

---

[៤១] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទឡ្ហីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឲ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

[៤២] សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Lubanga សំណុំរឿងលេខ ICC-01/04-01/06 *សេចក្តីសម្រេចកោសល្យបរអំពី "សំណើរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍"* ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ កថាខណ្ឌ ១៦៥-១៦៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Lubanga សំណុំរឿងលេខ ICC-01/04-01/06 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក* Thomas Lubanga Dyilo *ប្រឆាំងនឹងសេចក្តីសម្រេចអំពីការជំទាស់របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការតុលាការ យោងតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦* ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ២៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Bemba សំណុំរឿងលេខ ICC-01/05-01/08 *សេចក្តីសម្រេចលើ "សំណើរបស់មេធាវីការពារក្តីសុំការអនុញ្ញាតប្តឹងឧទ្ធរណ៍ប្រឆាំងនឹង "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំសំណងចំពោះការរំលោភលើដំណើរការ""* ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ កថាខណ្ឌ ១២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២។ រឿងក្តី *Barayagwiza តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-97-19-AR72 *សេចក្តីសម្រេច* ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៣, ៧៦-៧៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Nikolić សំណុំរឿងលេខ IT-94-2-PT *សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីសុំជំទាស់នឹងការអនុវត្តយុត្តាធិការរបស់តុលាការ* ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ ១១១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៤។ នៅក្នុងរឿងក្តីប្រឆាំងនឹង *Florence Hartmann* សំណុំរឿងលេខ IT-02-54-R77.5 *សំអាងហេតុអំពីញត្តិរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីចំពោះ*

៣៧. អោ អាន ត្រូវបានផាត់ចេញពីការចូលទៅពិនិត្យសំណុំរឿង ឬពីការចូលរួមក្នុងការស៊ើបអង្កេត ជាច្រើនឆ្នាំ។ នៅក្នុងអំឡុងពេលនេះ ខណៈដែលសហព្រះរាជអាជ្ញាអន្តរជាតិទទួលបានសិទ្ធិចូលរួមកិច្ចស៊ើបសួរពេញលេញ និងមានលទ្ធភាពបង្កើតការស៊ើបអង្កេត និងកសាងសំណុំរឿងប្រឆាំងនឹង អោ អាន, អោ អាន វិញពុំទទួលបានសិទ្ធិអ្វីទាំងអស់។ បន្ទាប់ពីមានការពិភាក្សាលេចឮជាសាធារណៈអំពីឧក្រិដ្ឋកម្មដែលចោទប្រកាន់ថាគាត់បានប្រព្រឹត្តនោះ ទើបចុងក្រោយនៅក្នុងខែកុម្ភៈ ឆ្នាំ២០១២ អោ អាន ត្រូវបានជូនដំណឹងអំពីការចោទប្រកាន់នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ហើយគាត់ត្រូវរង់ចាំ៣(បី)ឆ្នាំទៀត មុនពេលគាត់ដឹងអំពីលក្ខណៈ និងមូលហេតុជាក់លាក់នៃបទចោទនានាលើរូបគាត់។ មន្ត្រីតុលាការម្នាក់ជូនដំណឹងគាត់អំពីសិទ្ធិរបស់ក្នុងការមានការតំណាងដោយមេធាវី តាមការជ្រើសរើសរបស់គាត់ ខណៈដែលមន្ត្រីតុលាការម្នាក់ទៀតបដិសេធតាមទំនើងចិត្តនូវសិទ្ធិនោះអស់រយៈពេល៤(បួន)ខែកន្លះ។ ចុងក្រោយ នៅពេលគាត់ត្រូវបានគេអនុញ្ញាតឲ្យចូលពិនិត្យមើលសំណុំរឿង អោ អាន រកឃើញថាទ្រឹស្តីសំណុំរឿងត្រូវបានបង្កើតរួចបាត់ទៅហើយ ហើយភស្តុតាងគាំទ្រភាគច្រើនត្រូវបានប្រមូលរួចជាស្រេច ដែលធ្វើឲ្យគាត់ចូលរួមក្នុងកិច្ចស៊ើបសួរដោយហឺអើប៉ុណ្ណោះ។

៣៨. ខណៈដែលវិធាននៃការសម្រេចដោយមតិភាគច្រើនលើសលប់អនុញ្ញាតឲ្យចៅក្រមភាគតិចរុញសំណុំរឿងនេះឲ្យដំណើរការទៅមុខ ដែលជាក់ស្តែងនាំឲ្យសច្ចធារណ៍និរទោសរបស់គាត់គ្មានន័យខ្លឹមសារអ្វីនោះ អោ អាន ព្យាយាមបង្កើតនិរទោសរបស់គាត់។ ការប៉ុនប៉ងរបស់គាត់ក្នុងការស្វែងរកភស្តុតាងដោះបន្ទុក ត្រូវបានរារាំងដោយចៅក្រមម្នាក់ដែលយល់ឃើញថា ភស្តុតាងបែបនេះមិនត្រូវតាមទ្រឹស្តីសំណុំរឿងដែលបានបង្កើតរួចហើយនោះទេ ដែលចៅក្រមរូបនោះបានរងសម្ពាធដោយកង្វះថវិការ៉ាំរ៉ៃ និងសម្ពាធពីម្ចាស់ជំនួយដើម្បីបញ្ចប់កិច្ចស៊ើបសួរ។ រាល់ការប៉ុនប៉ងប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធបែបនេះ ត្រូវបានរារាំងដោយការបដិសេធទាំងស្រុងទៅលើបណ្តឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសំណើសុំបើកកិច្ចស៊ើបសួរពីសំណាក់ចៅក្រមជាតិបីរូបរបស់អង្គបុរេជំនុំជម្រះ។ ទន្ទឹមគ្នានេះដែរ ភស្តុតាងទទួលបានពីសាក្សីនៅក្នុងសំណុំរឿងត្រូវបានប្រឡាក់ប្រឡូកដោយការធ្វេសប្រហែស និងភាពលម្អៀងរបស់អ្នកស៊ើបអង្កេត ឬការផ្តល់សាក្ខីកម្មដោយសាក្សីនៅក្នុងសវនាការក្នុងសំណុំរឿង០០២។ នៅពេលបញ្ចប់ការស៊ើបអង្កេត អោ អាន ទទួលបានដីកាដំណោះស្រាយពីរផ្ទុយគ្នា ហើយគាត់ត្រូវបានគេទុកឲ្យស្មានអំពីលក្ខណៈ និងមូលហេតុនៃបទចោទ

---

*ការរំលោភលើដំណើរការនីតិវិធី* ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៥។

មកលើរូបគាត់[៤៣]។ លើសពីនេះទៀត ដូចដែលបានបញ្ជាក់ជាឯកច្ឆ័ន្ទពីអង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតខកខានពុំបានបញ្ចប់ដំណាក់កាលស៊ើបសួរនៅក្នុងពេលវេលាសមស្រប[៤៤]។

៣៩. ទម្ងន់ត្រួតគ្នានៃកំហុសទាំងឡាយនេះ ច្បាស់ណាស់បង្កើតបានជា "ភាពមិនត្រឹមត្រូវដែលនាំទៅដល់ភាពអយុត្តិធម៌"[45]។ ខណៈដែលការរំលោភបំពាននីមួយៗប៉ះពាល់ដល់លទ្ធភាពរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នោះ *ផលប៉ះពាល់ជារួម*ដែលកើតចេញពីការរំលោភបំពានទាំងនេះធ្វើឱ្យអន្តរាយដល់ភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី តាមរបៀបមួយដែលអាក្រក់បំផុត និងមិនអាចជួសជុលបាន ដែលបណ្តាលឱ្យមានការជំនុំជម្រះក្តីដោយយុត្តិធម៌នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនអាចដំណើរការទៅបាន[46]។

៤០. យោងតាមសំអាងហេតុទាំងនេះ អង្គជំនុំជម្រះសាលាដំបូង ត្រូវបានស្នើសុំឱ្យតម្កល់សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អោ អាន និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទាំងនេះ ដោយរំលត់បណ្តឹងអាជ្ញាមួយនេះ។

## សេចក្តីសន្និដ្ឋាន និងសំណើ

៤១. ផ្ទុយទៅនឹងការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ក្របខណ្ឌច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមានចែងអំពីដំណោះស្រាយច្បាស់លាស់ចំពោះអត្ថិភាពនៃដីកាដំណោះស្រាយផ្សេងពីគ្នា និងផ្ទុយគ្នាឡើយ បន្ទាប់ពីអង្គបុរេជំនុំជម្រះមិនអាចរកបានសម្លេងភាគច្រើនលើសលប់ដើម្បីសម្រេចលើអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍របស់ភាគី។ នៅក្នុងករណីវិមតិសង្ស័យគ្មានច្បាប់ចែងបែបនេះ សំណុំរឿងត្រូវតែដោះស្រាយដើម្បីជាប្រយោជន៍ដល់ អោ អាន

[៤៣] មេធាវីការពារក្តីត្រៀមខ្លួនរួចជាស្រេចក្នុងការផ្តល់នូវព័ត៌មានពិស្តារពេញលេញ ពាក់ព័ន្ធនឹងទស្សីករណ៍នេះ នៅក្នុងសារណាបន្ថែមទៀត ប្រសិនបើ អង្គជំនុំជម្រះសាលាដំបូង ផ្តល់ការអនុញ្ញាតឱ្យដាក់សារណាបន្ថែមទៀតលើបញ្ហានេះ។

[៤៤] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ កថាខណ្ឌ ៦២, ៧២។

[៤៥] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Bemba សំណុំរឿងលេខ ICC-01/05-01/08-3636-ឧបសម្ព័ន្ធ៣ *យោបល់ឯកភាពដាច់ដោយឡែករបស់ចៅក្រម* Eboe-Osuji ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៨៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៦។

[៤៦] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/អជតក(០៨) សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ នួន ជា ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ ឯកសារ **E116/1/7** ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ២០១២ កថាខណ្ឌ ២៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៧។

ដោយអនុលោមតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា។ អាស្រ័យហេតុនេះ មេធាវីការពារក្ដីស្នើសុំ ដោយគោរពឱ្យអង្គជំនុំជម្រះសាលាដំបូង ដោះស្រាយបញ្ចប់បញ្ហានេះទាំងស្រុង ដោយបញ្ជាក់ថា ខ្លួនមិនបានទទួលយកសំណុំរឿងប្រឆាំងនឹង អោ អាន មកជំនុំជម្រះដោយស្របច្បាប់នោះឡើយ។

៤២. ប្រសិនបើសំណើខាងលើនេះបរាជ័យ មេធាវីការពារក្ដីស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង ពិចារណាលើសេចក្ដីសង្ខេបអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩(១)នៃវិធានផ្ទៃក្នុងនេះ និងស្នើសុំ ឱ្យអង្គជំនុំជម្រះសាលាដំបូងផ្ដល់ពេលវេលាបន្ថែមចំនួន៦០ថ្ងៃ និងបង្កើនចំនួនទំព័រ១២០ទំព័រ ឱ្យ មេធាវីការពារក្ដីដើម្បីដាក់ទឡ្ហីករណ៍ពេញលេញនៅក្នុងអញ្ញត្រកម្មនីមួយៗ។

៤៣. មេធាវីការពារក្ដីសូមអះអាងថាអញ្ញត្រកម្មដែលបានលើកឡើងនៅក្នុងសារណានេះ បង្ហាញនូវ វិការៈយ៉ាងច្បាស់ដែលតម្រូវឱ្យមានការពិនិត្យពិច័យ និងការសម្រេចជាបន្ទាន់ពីអង្គជំនុំជម្រះ សាលាដំបូង។ ការពន្យារពេលចេញសេចក្ដីសម្រេចលើអញ្ញត្រកម្មទាំងនេះ រហូតដល់បញ្ចប់កិច្ច ដំណើរការនីតិវិធីជំនុំជម្រះ ជាការផ្ទុយទៅនឹងប្រយោជន៍យុត្តិធម៌ និងជាការមាក់ងាយដល់ សេដ្ឋកិច្ចតុលាការ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២០ ខែមករា ឆ្នាំ២០២០

**សហមេធាវីការពារក្ដីរបស់លោក អោ អាន**

| | | |
|---|---|---|
| មុំ លុដ្ឋ | Richard ROGERS | Göran SLUITER |